លោកអ្នកត្រូវចាក់ថ្នាំសំខាន់ទាំងបីនេះដើម្បីបង្ការរោគ។ ការចាក់ថ្នាំបង្ការនេះ ជាទូទៅចាក់ក្នុងរយៈពេលលើសពីប្រាំមួយខែ។

---

ដើម្បីការពារខ្លួនរបស់លោកអ្នកឲ្យផុតពីរោគរលាកថ្លើម B លោកអ្នកត្រូវតែចាក់ថ្នាំបង្ការនេះ។

---

## តើនៅកន្លែងណាខ្ញុំអាចទៅចាក់ថ្នាំបង្ការរោគរលាកថ្លើម B នេះបាន ?

សុំឲ្យលោកវេជ្ជបណ្ឌិតចាក់បង្ការរោគទាំងអស់នេះ។ មានមន្ទីរព្យាបាលសុខភាពខ្លះ នៅតាមសាលារៀនមានចាក់ថ្នាំបង្ការនេះដែរ។ បើសិនជាលោកអ្នកគ្មានវេជ្ជបណ្ឌិត ឬមន្ទីរព្យាបាល ឬមិនអាចបង់ថ្លៃចាក់ថ្នាំបាន ចូរទាក់ទងមកក្រសួងសុខាភិបាលក្រុង ឬខោនធីភ្លាម។

## តើខ្ញុំត្រូវចាក់ថ្នាំបង្ការរោគផ្សេងៗទៀតទេ ?

ប្រហែលជាត្រូវ។ ការចាក់ថ្នាំវ៉ាក់សុីនអាចការពាររោគបានច្រើន រួមចូលរោគតេតាណូស, រោគអុតស្វាយ, រោគកញ្រ្ជិល, រោគក្រទ្បទែន, រោគស្អូច, រោគរលាកថ្លើម A, គ្រុនផ្តាសាយធំ ហើយនឹងរោគរលាកស្អូត។ ចូរសួរអ្នកផ្តល់ការព្យាបាលសុខភាព ដើម្បីចង់ដឹងថាត្រូវចាក់ថ្នាំបង្ការរោគណាមួយ។

Hepatitis B Coalition
Immunization Action Coalition
1573 Selby Avenue
St. Paul, MN 55104
651-647-9009
www.immunize.org

ពាក្យពេចន៍នៅលើកូនសៀវភៅនេះ បានពិនិត្យកែតម្រូវដោយមណ្ឌលត្រួតពិនិត្យនឹងការពាររោគ (Centers for Disease Control and Prevention) ។ កូនសៀវភៅនេះគ្មានរក្សាសិទ្ធិទេ ដូច្នេះ លោកអ្នកអាចចំឡងយកទៅប្រើសំរាប់មន្ទីរព្យាបាល ឬសហគមន៍បាន។ ក៏ប៉ុន្តែ សូមលោកអ្នកទទួលស្គាល់នូវស្នាដៃក្រសួងសហពលកម្មការពាររោគរលាកថ្លើម B (Hepatitis B Coalition) ដែលជារៀបចំផង។

Item #P4100-03 Cambodian (6/97)

# រាល់សប្តាហ៍ មានក្មេងជំទង់ រាប់រយនាក់ បានកើតរោគ រលាកថ្លើម B



# ចាក់ថ្នាំ វ៉ាក់សុីនបង្ការ រោគនេះ !!

# អ្វីទៅរោគរលាកថ្លើម B នោះ?

រោគរលាកថ្លើម B គឺជារោគថ្លើមមួយយ៉ាងធ្ងន់ធ្ងរ ដែលកើតឡើងដោយមេរោគ។ មេរោគអាចហូរចូលទៅក្នុងឈាម ប្រឆាំងនឹងថ្លើម ហើយធ្វើឲ្យកើតរោគធ្ងន់ធ្ងរ - ដល់ទៅស្លាប់។ ក្នុងករណីខ្លះ មេរោគអាចនៅខ្លួនអស់មួយជីវិត ហើយធ្វើឲ្យខូចថ្លើមរហូត - រួមចូលរោគមហារីកថ្លើម។

---

**A.J.** មានអាយុ 15 ឆ្នាំ នៅពេលនាងស្លាប់ដោយសាររោគរលាកថ្លើម B ។ គ្រួសាររបស់នាង មានគោលបំណងយ៉ាងធំចំពោះនាង។ ការចាក់ថ្នាំបីម្ដងលបង្ការ ប្រហែលជាអាចជួយជីវិតរបស់នាងបាន។

---

# តើក្មេងជំទង់កើតរោគរលាកថ្លើម B ដោយរបៀបណា?

មានរបៀបច្រើន។ រោគរលាកថ្លើម B ឆ្លងដោយ :

- កាមគុណ
- ប្រើម្ជុលចូលគ្នា, ច្រាសដុះធ្មេញ ឬ ឡាមកោរពុកមាត់
- មានទាក់ទងជាប់ឈាមអ្នកណាម្នាក់
- ប្រើម្ជុលចារសាក់ ឬ ចោះត្រចៀក

លោកអ្នក **មិន** ឆ្លងរោគរលាកថ្លើម B ពីកណ្ដាស, ក្អក, ឬកាន់ដៃគ្នានោះឡើយ។

# តើខ្ញុំនឹងឈឺគ្រុនធ្ងន់ធ្ងរឬ បើសិនជាខ្ញុំកើតរោគរលាកថ្លើម B ?

មនុស្សម្នាក់ៗ មានអាការរោគខុសៗគ្នា។ លោកអ្នកអាចឈឺគ្រុនធ្ងន់ធ្ងរ (មានមនុស្សម្នាក់ រាល់មនុស្សបីនាក់ឈឺគ្រុនធ្ងន់ធ្ងរ)។ អាការរោគរបស់លោកអ្នកប្រហែលជាមានដូចតទៅនេះ :

- ស្បែកនឹងភ្នែកឡើងពណ៌លឿងព្រឿងៗ
- ប៉ោងពោះដែលធ្វើឲ្យឈឺចាប់
- បរិភោគមិនបាន អស់កម្លាំងកំហែង
- មានអារម្មណ៍ចង់តែក្អួត
- គ្រុនក្ដៅ
- ទឹកនោមឡើងពណ៌ខ្មៅ
- ឡើងកន្ទួលក្រហមពេញខ្លួន

មានមនុស្សខ្លះកើតរោគនេះ គ្មានឈឺគ្រុនអ្វីឡើយ។ ពួកគេនេះក៏នូវតែអាចធ្វើឲ្យរោគនេះឆ្លងទៅអ្នកដទៃ ហើយនឹងមានរោគថ្លើមធ្ងន់ធ្ងរពេលក្រោយផង។

---

ជនជាតិអាមេរិកកើតរោគរលាកថ្លើម B ម្នាក់ រាល់មនុស្ស 20 នាក់ ក្នុងមួយជីវិតរបស់មនុស្សម្នាក់ៗ។

---

# តើមានមនុស្សច្រើនកើតរោគរលាកថ្លើម B ឬ ?

រាល់ឆ្នាំមានមនុស្សជាងមួយភាគបួនលាននាក់កើតរោគរលាកថ្លើម B។ ជាងមួយលាននាក់នៅសហរដ្ឋមានមេរោគនៅក្នុងឈាម។ រៀងរាល់សប្ដាហ៍មានក្មេងជំទងរាប់រយនាក់កើតរោគរលាកថ្លើម B នេះ។

# តើឲ្យខ្ញុំការពារឲ្យផុតពីរោគរលាកថ្លើម B យ៉ាងណា ?

ដើម្បីការពារខ្លួនឲ្យផុតពីរោគរលាកថ្លើម B លោកអ្នកត្រូវចាក់ថ្នាំការពារបីម្ដង។ ថ្នាំចាក់វ៉ាក់សុីនបង្ការរោគរលាកថ្លើម B គឺជាថ្នាំមានសន្តិសុខល្អណាស់។ ថ្នាំបានប្រើនៅសហរដ្ឋអាមេរិកតាំងពីឆ្នាំ 1982 ហើយក៏បង្ហាញនូវការសុខស្រួលនេះរហូតមក។ ធ្វើយ៉ាងណា